# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ   សាសនា   ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៨-០២៨ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកំណត់ទុនអប្បបរមាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពី ការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ
- យោងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ
- យោងប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់ទ្រនាប់ដើមទុន ដែលរួមមានដើមទុនខនស៊ើវេសិន (Capital Conservation) និងដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital) ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅ៖

- ពង្រឹងមូលដ្ឋានដើមទុនសម្រាប់បំពេញការខាតបង់នានាដែលអាចកើតឡើងពីហានិភ័យរបស់គ្រឹះស្ថាន
- បង្ការការធ្លាក់ចុះដើមទុនមិនឲ្យទាបជាងកម្រិតដើមទុនអប្បបរមា និង
- កាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុ និងវដ្តសេដ្ឋកិច្ច (Pro-cyclicality)។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប ប្រសិនបើមាន។ គ្រឹះស្ថានដែលមានកម្រិតគួបសរុបត្រូវអនុវត្តដូចគ្នានឹងការគណនាគួបសរុបក្នុងរបាយការណ៍ស្តីពី អនុបាតសាធនភាព។

**ប្រការ ៤.-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ដើមទុនថ្នាក់ទី ១** សំដៅដល់ដើមទុនថ្នាក់ទី១ ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ដើមទុនថ្នាក់ទី ២** សំដៅដល់ដើមទុនថ្នាក់ទី២ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ដើមទុនសរុប** សំដៅដល់ "មូលនិធិផ្ទាល់សុទ្ធ" ដូចមានចែងក្នុងប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ដើមទុនសរុបរបស់គ្រឹះស្ថានគឺជាផលបូករវាងដើមទុនថ្នាក់ទី១ និងដើមទុនថ្នាក់ទី២។

**ទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ** សំដៅដល់ផលបូកនៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។